**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ល្បឿនសម្រាប់យានជំនិះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់ល្បឿនបើកបរអតិបរមាសម្រាប់យានជំនិះគ្រប់ប្រភេទ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅ៖

- រក្សាសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ទប់ស្កាត់ការបើកបរយានជំនិះហួសល្បឿនកំណត់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក
- លើកកម្ពស់ការយល់ដឹង និងការចូលរួមពីគ្រប់មជ្ឈដ្ឋាន ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការធ្វើចរាចរណ៍យានជំនិះគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

វាក្យស័ព្ទដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

– **ទីប្រជុំជន** សំដៅដល់ទីកន្លែងដែលមានអគារ ឬ គេហដ្ឋានសង់ជិតៗគ្នា ហើយផ្លូវចេញ ឬ ចូលនៅទីនោះមានដាក់ផ្លាកសញ្ញាប្រាប់ទីប្រជុំជន ឈ្មោះទីប្រជុំជនសម្គាល់ការចូល ឬ ឈ្មោះទីប្រជុំជនដែលមានគំនូសបន្ទាត់ទ្រូងពណ៌ក្រហមសម្គាល់ការចេញពីទីប្រជុំជនតាមដងផ្លូវ និងមានមនុស្សធ្វើចរាចរណ៍ឆ្លងកាត់ទៅមកច្រើន

– **រថយន្តធុនស្រាល** សំដៅដល់រថយន្តដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ៣,៥ (បីក្បៀសប្រាំ)តោន

– **រថយន្តដឹកទំនិញធុនធ្ងន់** សំដៅដល់រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥(បីក្បៀសប្រាំ)តោន

– **យានយន្តកសិកម្មកែច្នៃ** សំដៅដល់យានយន្តឧបករណ៍កែច្នៃសម្រាប់បំរើការងារកសិកម្ម ដូចជាយានយន្តច្រូតស្រូវ យានយន្តបោកបែនស្រូវ និងយានយន្តកិនស្រូវជាអាទិ៍

– យានយន្តឧបករណ៍ សំដៅដល់យានយន្តពិសេសដែលមានឧបករណ៍គ្រឿងចក្របំពាក់បន្ថែម គ្មានផ្ទុកមនុស្ស ឬ គ្មានផ្ទុកទំនិញនៅក្រៅកាប៊ីន ។ យានយន្តឧបករណ៍មានពីរប្រភេទៈ

ប្រភេទទី១ យានយន្តឧបករណ៍ដែលមានល្បឿនអតិបរមាត្រឹម ៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោងដូចជាត្រាក់ទ័រ គ្រឿងចក្រសម្រាប់សាងសង់ផ្លូវ ស្ពានជាអាទិ៍។

ប្រភេទទី២ យានយន្តឧបករណ៍ដែលមានល្បឿនអតិបរមាលើស ៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោង ដូចជា រថយន្តលាយស៊ីម៉ងត៍ រថយន្តបូមល្បាយបេតុង រថយន្ត ស្ទូច ជាអាទិ៍។

## ជំពូកទី២
## ការកំណត់ល្បឿនសម្រាប់យានជំនិះ

**មាត្រា៥.-**

លក្ខខណ្ឌសម្រាប់បើកបរយានជំនិះនៅតាមផ្លូវថ្នល់ មានដូចខាងក្រោមៈ

១-អ្នកបើកបរត្រូវប្រើប្រាស់ល្បឿនស្របតាមផ្លាកសញ្ញាកំណត់ល្បឿនអតិបរមានៅតាមដងផ្លូវ។

២-នៅកន្លែងដែលពុំមានផ្លាកសញ្ញាកំណត់ល្បឿន អ្នកបើកបរត្រូវប្រើប្រាស់ល្បឿនអតិបរមាដូចខាងក្រោមៈ

ក- នៅក្នុងទីប្រជុំជនល្បឿនអតិបរមា ត្រូវកំណត់ត្រឹមៈ

– ៣០(សាមសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ទោចក្រយានយន្ត ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ត្រីចក្រយានយន្ត ត្រាក់ទ័រ យានយន្តកសិកម្ម និងសម្រាប់យានយន្តឧបករណ៍ដែលមានល្បឿនអតិបរមាត្រឹម ៤០(សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង

– ៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោង សម្រាប់រថយន្តគ្រប់ប្រភេទ និងសម្រាប់យានយន្តឧបករណ៍ដែលមានល្បឿនអតិបរមាលើស ៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោង។

ខ- នៅក្រៅទីប្រជុំជនល្បឿនអតិបរមា ត្រូវកំណត់ត្រឹមៈ

– ៤០(សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ត្រីចក្រយានយន្ត ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ត្រាក់ទ័រ យានយន្តកសិកម្ម និងយានយន្តឧបករណ៍ដែលមានល្បឿនអតិបរមាត្រឹម ៤០(សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង

– ៦០(ហុកសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ទោចក្រយានយន្ត ដែលមានទំហំស៊ីឡាំងមិនលើសពី ១២៥(មួយរយម្ភៃប្រាំ)សង់ទីម៉ែត្រគូប យានយន្តឧបករណ៍ដែលមានល្បឿនអតិបរមាលើស ៤០(សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង រថយន្តសណ្តោងរ៉ឺម៉ក ឬ សឺមីរ៉ឺម៉ក និងរថយន្តដឹកកុងតែន័រគ្រប់ប្រភេទ

- ៧០(ចិតសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងលើសពី ១២៥(មួយរយម្ភៃប្រាំ)សង់ទីម៉ែត្រគូប និងរថយន្តដឹកទំនិញធុនធ្ងន់
- ៨០(ប៉ែតសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់រថយន្តធុនស្រាល និងរថយន្តដឹកអ្នកដំណើរ
- ៩០(កៅសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់រថយន្តធុនស្រាល និងរថយន្តដឹកអ្នកដំណើរបើកបរនៅលើផ្លូវដែលមានខឿនបែងចែកទិសចរាចរណ៍ជាពីរ ហើយមានគន្លងផ្លូវចាប់ពីបួនឡើងទៅ។

បទប្បញ្ញត្តិដែលមានចែងក្នុងចំណុចទី១ និងចំណុចទី២ នៃមាត្រានេះ មិនអនុវត្តចំពោះអ្នកបើកបរយានយន្តក្បួននគរបាល យោធា កងរាជអាវុធហត្ថ គណៈប្រតិភូ ថ្នាក់ដឹកនាំជាន់ខ្ពស់ យានយន្តពន្លត់អគ្គិភ័យ យានយន្តសង្គ្រោះរបស់មន្ទីរពេទ្យ និងយានខ្លះទៀតដែលមានការអនុញ្ញាតឲ្យបន្លឺសូរសព្ទ ភ្លើងសញ្ញាពិសេស នៅពេលកំពុងបំពេញភារកិច្ចឡើយ។

**មាត្រា៦.-**

អ្នកបើកបរត្រូវគ្រប់គ្រងលើល្បឿនបើកបររបស់ខ្លួនជានិច្ច ហើយត្រូវបើកបរក្នុងល្បឿនសមស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីអាចបញ្ឈប់យានជំនិះបានទាន់ពេលវេលា និងដោយគ្មានគ្រោះថ្នាក់។

អ្នកបើកបរត្រូវបន្ថយល្បឿន ក្នុងករណីដូចខាងក្រោម៖

- ក្នុងគ្រប់ករណីដែលមានផ្លាកសញ្ញាឲ្យបន្ថយល្បឿន ឬ ផ្លាកសញ្ញាគ្រោះថ្នាក់
- ពេលមានមនុស្ស ឬ រទេះជនពិការឆ្លងកាត់ផ្លូវ
- ពេលជៀសគ្នាលើផ្លូវចង្អៀត
- ពេលជៀសរថយន្តដឹកជញ្ជូនអ្នកដំណើរ ឬ រថយន្តដឹកជញ្ជូនកុមារ ដែលកំពុងឈប់ដាក់អ្នកដំណើរ ឬ កុមារឡើងចុះ
- ពេលជៀស ឬ ជែងក្បួនយានកំពុងឈប់ ឬ នៅពេលជៀស ឬ ជែងក្បួនដង្ហែផ្សេងៗ
- ពេលទៅជិតដល់ស្ពាន ឬ ជិតដល់ផ្លូវរថភ្លើងឆ្លងកាត់
- ពេលប្តូរទិសចរាចរណ៍
- កន្លែងផ្លូវបត់ ផ្លូវកោង ផ្លូវរអិល ផ្លូវប្រសព្វ រង្វង់មូល ឬ ការដ្ឋានសាងសង់ ជួសជុលថែទាំផ្លូវ
- កន្លែងមានសាលារៀន មន្ទីរពេទ្យដែលមានទីតាំងស្ថិតនៅក្បែរផ្លូវ

– ពេលជិតដល់ទួលខ្ពស់ ឬ ពេលចុះចំណោត

– ពេលអាកាសធាតុមិនល្អដែលមិនអាចមើលឃើញបានឆ្ងាយនិងច្បាស់ល្អ

– ពេលមានវត្ថុជាឧបសគ្គ ឬ មានផ្ទះច្រើនកៀកជាប់ទ្រូងផ្លូវ

– ពេលមានយានយន្តរបស់នគរបាល យោធា កងរាជអាវុធហត្ថ គណៈប្រតិភូ ថ្នាក់ដឹកនាំជាន់ខ្ពស់ យានយន្តពន្លត់អគ្គិភ័យ យានយន្តសង្គ្រោះរបស់មន្ទីរពេទ្យ និងយានខ្លះទៀតដែលមានការអនុញ្ញាតឲ្យបន្លឺសូរសព្ទ ភ្លើងសញ្ញាពិសេស នៅពេលកំពុងបំពេញភារកិច្ច អ្នកបើកត្រូវបន្ថយល្បឿន និងបើកបរអែបទៅខាងស្តាំ បើចាំបាច់ត្រូវឈប់នៅផ្នែកខាងស្តាំបំផុតដែលអាចធ្វើទៅបានដើម្បីសម្រួលឲ្យយានយន្តទាំងនោះធ្វើចរាចរណ៍ដោយសុវត្ថិភាព។

**មាត្រា៧.-**

អ្នកបើកបរមិនត្រូវប្រើល្បឿនយឺតខុសប្រក្រតីដោយគ្មានមូលហេតុត្រឹមត្រូវ ដែលធ្វើឲ្យរំខានដល់យានជំនិះដទៃទៀតទេ។ អ្នកបើកបរដែលប្រើល្បឿនយឺត ត្រូវបើកបរអែបទៅខាងស្តាំ ដើម្បីទុកឲ្យអ្នកបើកបរដែលប្រើល្បឿនលឿនជែងពីខាងឆ្វេងដៃបានដោយងាយស្រួល។

អ្នកបើកបរណាដែលត្រូវបង្ខំចិត្តបន្ថយល្បឿនឲ្យយឺតខុសប្រក្រតី ត្រូវឲ្យដំណឹងដល់អ្នកបើកបរផ្សេងទៀតដោយប្រើភ្លើងសញ្ញាអាសន្ន ហើយត្រូវបើកបរអែបទៅខាងស្តាំបំផុតនៃទ្រូងផ្លូវ។

**មាត្រា៨.-**

សមត្ថកិច្ចទទួលបន្ទុកវិស័យផ្លូវថ្នល់ ត្រូវ៖

– បំពាក់ផ្លាកសញ្ញាកំណត់ល្បឿនឲ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសមស្របតាមស្ថានភាពជាក់ស្តែងរបស់ផ្លូវថ្នល់

– សហការជាមួយស្ថាប័ន ឬ អាជ្ញាធរដែនដីដែលពាក់ព័ន្ធ បំពាក់ផ្លាកសញ្ញាប្រាប់ការចូលចេញទីប្រជុំជនឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសមស្របតាមស្ថានភាពជាក់ស្តែងរបស់ផ្លូវថ្នល់ ដែលអាចឲ្យអ្នកបើកបរមើលឃើញច្បាស់ល្អ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..០៨..ខែ..កក្កដា..ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជាសូមហត្ថលេខា។

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ